ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
លេខ : ........៤២ បទ.ផ.ស.ក...........

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រើលេខកូដរួម *1200# *1201# *1202# *1203* PIN# និង 1204 សម្រាប់ប្រើប្រាស់គ្រប់ប្រព័ន្ធទូរសព្ទចល័ត

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ ឱ្យបានជ្រាបថា ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់សេវាទូរសព្ទចល័តទាំងអស់ និយ័តករទូរគមនាគមន៍កម្ពុជាបានតម្រូវឱ្យប្រតិបត្តិករផ្តល់សេវាទូរសព្ទចល័តនៅទូទាំងប្រទេស រៀបចំលេខកូដរួមដែលមានលក្ខណៈស្តង់ដារ ស្របតាមលេខកូដទូរគមនាគមន៍ជាតិ ដែលមានមុខសញ្ញាប្រើប្រាស់ ដូចខាងក្រោម៖

| ល.រ | លេខកូដ | ការប្រើប្រាស់ | របៀបប្រើប្រាស់ |
|---|---|---|---|
| ១ | *1200# | ផ្តាច់សេវាបន្ថែម (VAS) ដែលមិនត្រូវការប្រើ | ចុច *1200# រួចចុចបញ្ជូន |
| ២ | *1201# | ពិនិត្យសមតុល្យទឹកប្រាក់ | ចុច *1201# រួចចុចបញ្ជូន |
| ៣ | *1202# | ពិនិត្យអត្តសញ្ញាណអ្នកប្រើប្រាស់ | ចុច *1202# រួចចុចបញ្ជូន |
| ៤ | *1203*PIN# | បញ្ចូលទឹកប្រាក់ | ចុច*1203*PIN# រួចចុចបញ្ជូន |
| ៥ | 1204 | ទាក់ទងទៅកាន់សេវាបម្រើអតិថិជន | ចុច 1204 រួចចុចបញ្ជូន |

ដូចនេះ សាធារណជនអាចប្រើប្រាស់លេខកូដទាំង៥ ខាងលើបាន**គ្រប់ប្រព័ន្ធទូរសព្ទចល័តទាំងអស់** ដើម្បីធ្វើការផ្តាច់សេវាបន្ថែម(Value Added Services) ដែលមិនត្រូវការប្រើ ពិនិត្យសមតុល្យទឹកប្រាក់ ពិនិត្យអត្តសញ្ញាណអ្នកប្រើប្រាស់ បញ្ចូលទឹកប្រាក់ ឬទាក់ទងទៅកាន់សេវាបម្រើអតិថិជនរបស់ក្រុមហ៊ុនទូរសព្ទចល័តនីមួយៗ ដោយឥតគិតថ្លៃ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ តទៅ។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងនិយ័តករទូរគមនាគមន៍កម្ពុជា តាមរយៈលេខទូរសព្ទ ៦៧៨៩ រៀងរាល់ម៉ោងធ្វើការ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១